# ជំពូកទី ១០

# ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀន

## គោលបំណងមេរៀន

អ្នកសិក្សានឹងអាចយល់ និងពន្យល់អំពីៈ

- ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់
- ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់គ្រឿងស្រវឹង
- ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់គ្រឿងញៀន
- ហេតុអ្វីបានជាមនុស្សមួយចំនួនចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ និងគ្រឿងស្រវឹង ខណៈពេលដែលដឹងថា វាបង្កគ្រោះថ្នាក់ដល់សុខភាពរបស់ពួកគេ
- ហេតុអ្វីបានជាមនុស្សពិបាកបញ្ឈប់ការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀន

នៅក្នុងជំពូកនេះ អ្នកនឹងរៀនពីផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀន និងកត្តាផ្សេងៗជាច្រើនទៀត។ ជាពិសេស អ្នកនឹងរៀនពីការរីករាលដាលនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀននៅក្នុងប្រទេសកម្ពុជា ព្រមទាំងរៀនអំពីអ្វីដែលអ្នកអាចធ្វើបានដើម្បីការពារសុខភាពយុវជនពីការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀនតាមរយៈការស្វែងយល់ពីការញៀនគ្រឿងញៀន ទំនាក់ទំនងរវាងការប្រើប្រាស់ថ្នាំជក់ និងសុខភាព និងទំនាក់ទំនងរវាងការប្រើប្រាស់គ្រឿងស្រវឹង និងសុខភាព។

## ១ ការប្រើប្រាស់ថ្នាំជក់ និងសុខភាព

### ១.១. ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់[1]

នៅពេលថ្នាំជក់កំពុងឆេះ វាបង្កើតធាតុផ្សំផ្សេងៗគ្នា (ឧទាហរណ៍ ឧស្ម័ន និងធាតុផ្សំល្អិតៗផ្សេងទៀត)។ ប្រសិនបើធាតុផ្សំទាំងនេះត្រូវបានស្រូបចូល វាចរាចរពាសពេញរាងកាយតាមរយៈឈាម និងបង្កអន្តរាយដល់សរីរាង្គជាច្រើននៃរាងកាយមនុស្ស (រូបទី ១០.១)។ ផ្សែងដែលស្រូបដោយអ្នកជក់បារីហៅថា **ផ្សែងហឺតពីបារី (mainstream smoke)** ហើយផ្សែងដែលចេញពីចុងបារីត្រូវបានគេស្គាល់ថាជា**ផ្សែងចំហេះបារី (sidestream smoke)**។ <u>ផ្សែងចំហេះបារីមានសារជាតិគីមីដែលបង្កគ្រោះថ្នាក់ច្រើនជាងផ្សែងបឺតបារីដែលត្រូវបានស្រូបតាមកន្ទុយតម្រងបារី</u>។ ហេតុនេះហើយបានជាការប្រើប្រាស់ថ្នាំជក់មាន**ផលប៉ះពាល់ដល់សុខភាព (health effects)** យ៉ាងធ្ងន់ធ្ងរមិនត្រឹមតែទៅលើអ្នកជក់បារីប៉ុណ្ណោះទេថែមទាំងប៉ះពាល់ដល់កូនៗ និងដៃគូរបស់ពួកគេដែលរស់នៅជាមួយអ្នកជក់បារី ហើយ**ការជក់ដោយប្រយោល (passive smoking)** នោះផងដែរ។

ចំពោះស្ត្រីមានផ្ទៃពោះ[2] ការជក់បារី និងការហិតផ្សែងបារីអាចបង្កើនលទ្ធភាពនៃការរលូតកូន និងការសម្រាលកូនមិនគ្រប់ខែ។ សារជាតិគីមីនៃថ្នាំជក់ដែលស្រូបដោយស្ត្រីមានផ្ទៃពោះប៉ះពាល់ដល់គភ៌ក្នុងផ្ទៃរបស់នាងតាមរយៈឈាម បង្កើនហានិភ័យនៃការ**សម្រាលកូនមានទម្ងន់ទាប (low-birth-weight baby)** (**មានទម្ងន់កំណើតតិចជាង ២ ៥០០ក្រាម**) ឬធ្វើឱ្យគភ៌អភិវឌ្ឍយឺត។ ដូច្នេះស្ត្រីបំបៅដោះកូនគួរយកចិត្តទុកដាក់ផងដែរចំពោះការជក់បារី និងការហិតផ្សែងបារី។ សារជាតិបង្កគ្រោះថ្នាក់ដែលមាននៅទឹកដោះរបស់ម្តាយមានកំហាប់ខ្ពស់ជាងនៅក្នុងឈាមរបស់ម្តាយពី ២-៣ដង និង

អាចបង្កគ្រោះថ្នាក់ដល់ទារក (ជាពិសេសសួត និងខួរក្បាល)។ លើសពីនេះទៅទៀត ការជក់បារីបានបង្ហាញឱ្យឃើញពីការថយចុះបរិមាណនៃការបញ្ចេញទឹកដោះរបស់ម្ដាយ។ សូមកត់សម្គាល់ថាអត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្ដាយត្រូវបានគេចាត់ទុកថាសំខាន់ជាងហានិភ័យនៃការជក់បារីរបស់ម្ដាយ។ ហេតុនេះហើយ គេបានណែនាំឱ្យបំបៅដោះកូនដោយទឹកដោះ។

ចំពោះមនុស្សវ័យក្មេងមានហានិភ័យសុខភាពផ្សេងៗដូចជា ផលប៉ះពាល់លើសកម្មភាពរាងកាយ និងកីឡា ការកើតជំងឺផ្លូវដង្ហើម ការឈានទៅការញៀនបារី ការកើនឡើងហានិភ័យនៃការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀនដូចជា កញ្ឆា និងកូកាអ៊ីន ហើយជាក់ស្ដែងកាលណាឆាប់ចាប់ផ្ដើមប្រើប្រាស់ថ្នាំជក់តាំងពីវ័យនៅក្មេង ហានិភ័យក្នុងការកើតមានជំងឺមហារីកសួតក៏កាន់តែខ្ពស់ដែរ។[3]




**រូបទី ១០.១៖** ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់

## ១.២. សារជាតិគីមីក្នុងថ្នាំជក់ដែលបង្កគ្រោះថ្នាក់

ផ្សែងបារីផ្ទុកសារជាតិគីមីប្រមាណជាង ៥ ៣០០ប្រភេទ ដែលក្នុងនោះប្រមាណពី ៥០-៧០ប្រភេទត្រូវបានបញ្ជាក់ថាជាសារជាតិបង្កមហារីក។ ក្នុងចំណោមធាតុផ្សំឧស្ម័ន **កាបូនម៉ូណូអុកស៊ីត (carbon monoxide)** ប្រកួតប្រជែងជាមួយអុកស៊ីសែនដើម្បីភ្ជាប់ទៅនឹងអេម៉ូក្លូប៊ីន (hemoglobin) នៅក្នុងគោលិកាក្រហម (erythrocytes) បន្ថយបរិមាណអុកស៊ីសែនដែលដឹកជញ្ជូនដោយគោលិកាក្រហម។ ប្រសិនបើស្ថានភាពខ្វះអុកស៊ីសែនរ៉ាំរ៉ៃនៅតែបន្ត នោះចំនួនកោសិកាឈាមក្រហមអាចកើនឡើងដើម្បីរក្សាការដឹកជញ្ជូនអុកស៊ីសែនដែលបង្កើនភាពខាប់ (viscosity) និងបង្កើនសម្ពាធឈាម។ **ជ័រថ្នាំជក់/ជ័របារី (Tar)** ដែលជាធាតុផ្សំភាគល្អិតគឺជាល្បាយសារជាតិគីមីចំរុះដែលមានសកម្មភាពបង្កមហារីកដោយប្រែក្លាយកោសិកាដែលមានសុខភាពល្អទៅជាកោសិកាមហារីក និងសកម្មភាពបង្កើនការវិវឌ្ឍជំងឺមហារីកដោយធ្វើឱ្យកោសិកាមហារីកលូតលាស់ច្រើន។ នីកូទីនដែលជាប្រភេទវត្ថុធាតុអាល់កាឡូអ៊ីត (សារជាតិដែលបន្សាបជាតិអាស៊ីតដើម្បីបង្កើតអំបិល) គឺជាសារជាតិពុលដែលអាចសម្លាប់មនុស្សបានដោយជាតិពុលខ្លាំងលើប្រព័ន្ធប្រសាទ។ បន្ទាប់ពីស្រូបចូលទៅក្នុងខ្លួនតាមរយៈផ្សែងថ្នាំជក់ សារជាតិនីកូទីនរាលដាលយ៉ាងឆាប់រហ័សពាសពេញរាងកាយ។ ដោយសារតែការញៀននឹងសារជាតិនីកូទីន (dependency on nicotine) វាធ្វើឱ្យគេពិបាកក្នុងការផ្ដាច់ទំលាប់ជក់បារីណាស់។ លើសពីនេះទៅទៀត វាមានសកម្មភាពតឿកសរសៃឈាមដ៏ខ្លាំងដែលធ្វើឱ្យសរសៃឈាមតូចចង្អៀត និងបង្កើនសម្ពាធឈាម។ បើទោះជានីកូទីនមិនត្រូវបានបង្ហាញថាជាសារជាតិបង្កមហារីក (carcinogenic) ក៏ដោយប៉ុន្តែសារជាតិនីត្រូសូអាមីន (nitrosoamines) ដែលត្រូវបានផលិតនៅពេលនីកូទីនត្រូវបានបំបែក/រំលាយនៅក្នុងរាងកាយត្រូវបានគេដឹងថាជាសារជាតិបង្កមហារីក។

## អត្ថបទដកស្រង់ ១០.១៖ ការលេចចេញនូវផលិតផលថ្នាំជក់ប្រើថ្ម/បារីអេឡិចត្រូនិច (HTPs) ដែលជាប្រភេទថ្នាំជក់ថ្មី[4]

***ផលិតផលថ្នាំជក់ប្រើថ្ម/បារីអេឡិចត្រូនិច (HTPs)*** *គឺជាផលិតផលថ្នាំជក់ដែលផលិតជាចំហាយភាគល្អិតតូចៗ (aerosols) ផ្ទុកជាតិនីកូទីន និងសារជាតិគីមីផ្សេងៗទៀតហើយត្រូវបានស្រូបចូលតាមមាត់ដោយអ្នកប្រើប្រាស់។ ផលិតផលទាំងនេះផ្ទុកសារជាតិគីមីនីកូទីនដែលញៀនខ្លាំង។ វាក៏មានផ្ទុកនូវសារជាតិបន្ថែម និងជារឿយៗត្រូវបានគេបន្ថែមរសជាតិ។ ផលិតផលទាំងនេះក៏ធ្វើឱ្យមនុស្សធ្វើត្រាប់តាមអាកប្បកិរិយាដូចការជក់បារីធម្មតាដែរ។ ផលិតផលទាំងនោះរួមមាន iQOS ពីក្រុមហ៊ុន Philip Morris International ផលិតផល PloomTECH ពីក្រុមហ៊ុនថ្នាំជក់អន្តរជាតិជប៉ុនផលិតផល Glo មកពីក្រុមហ៊ុនថ្នាំជក់អង់គ្លេសអាមេរិកាំង និងផលិតផល PAX ពីក្រុមហ៊ុន PAXLabs។ ផលិតផលទាំងនេះប្រើប្រព័ន្ធកម្ដៅដែលប្រើថ្មដើម្បីកម្ដៅថ្នាំជក់រហូតដល់ ៣៥០ អង្សាសេដើម្បីបង្កើតចំហាយដែលមានសារជាតិនីកូទីន។*

*បច្ចុប្បន្ននេះគ្មានភស្តុតាងណាមួយបង្ហាញថា ផលិតផលថ្នាំជក់ HTPs មានគ្រោះថ្នាក់តិចជាងផលិតផលថ្នាំជក់ធម្មតានោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាមួយចំនួនដែលឧបត្ថម្ភដោយឧស្សាហកម្មថ្នាំជក់បានអះអាងថាពួកគេកាត់បន្ថយយ៉ាងខ្លាំងនូវទម្រង់ក៏ដូចជាការប៉ះពាល់ទៅនឹងជាតុផ្សំដែលបង្កគ្រោះថ្នាក់និងអាចបង្កគ្រោះថ្នាក់ដោយបារីស្តង់ដារ។ បច្ចុប្បន្ននេះគ្មានភស្តុតាងណាមួយបង្ហាញថា ការកាត់បន្ថយការប៉ះពាល់សារជាតិគីមីទាំង នេះនាំឱ្យមានការថយចុះហានិភ័យចំពោះមនុស្សឡើយ។ ដូច្នេះដើម្បីផ្ទៀងផ្ទាត់ការអះអាងនៃការកាត់បន្ថយហានិភ័យ និងគ្រោះថ្នាក់ ចាំបាច់ត្រូវធ្វើការសិក្សាបន្ថែមទៀតដោយគ្មានទំនាស់ផលប្រយោជន៍។ លើសពីនេះទៅទៀត គេពុំមានភស្តុតាងគ្រប់គ្រាន់ទាក់ទងនឹងកម្រិតផលប៉ះពាល់នៃការជក់បារីប្រយោលដែលបណ្ដាលមកពីផលិតផល HTPs នៅឡើយទេ។ វាចាំបាច់ត្រូវមានការសិក្សាបន្ថែមដើម្បីវាយតម្លៃពីហានិភ័យនៃការប្រឈមនឹងការបញ្ចេញឧស្ម័នដែលបញ្ចេញចេញពីផលិតផល HTPs។*

*<u>គ្រប់ទម្រង់នៃការប្រើប្រាស់ថ្នាំជក់សុទ្ធតែបង្កគ្រោះថ្នាក់រួមទាំងផលិតផល HTPs</u>។ ថ្នាំជក់មានជាតិពុលពីធម្មជាតិ ហើយមានផ្ទុកសារជាតិបង្កមហារីក សូម្បីតែនៅក្នុងទម្រង់ធម្មជាតិរបស់វាក៏ដោយ។ ដូច្នេះផលិតផល HTPs គួរតែស្ថិតនៅក្រោមគោលនយោបាយ និងវិធានការបទបញ្ញត្តិដែលអនុវត្តចំពោះផលិតផលថ្នាំជក់ដទៃទៀតស្របតាមអនុសញ្ញាក្របខ័ណ្ឌអង្គការសុខភាពពិភពលោកស្ដីពីការត្រួតពិនិត្យថ្នាំជក់ (the WHO Framework Convention on Tobacco Control (FCTC))។[5]*

*នៅខែមីនា ឆ្នាំ២០២១ កាសែតភ្នំពេញប៉ុស្ដិ៍បានរាយការណ៍ថា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (the National Authority for Combating Drugs (NACD)) នៃប្រទេសកម្ពុជាបានណែនាំដល់គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធក៏ដូចជាអង្គការនានាឱ្យចាត់វិធានការបញ្ឈប់ជាបន្ទាន់លើការធ្វើអាជីវកម្ម និងប្រើប្រាស់ផលិតផលថ្នាំជក់ HTPs។[6]*

## អត្ថបទដកស្រង់ ១០.២៖ តើអ្វីជាទំនាស់ផលប្រយោជន៍ (conflict of interest (COI))?

*យើងលើកឧទាហរណ៍ពីការសិក្សាស្រាវជ្រាវមួយដែលទទួលការឧបត្ថម្ភពីឧស្សាហកម្មថ្នាំជក់។ ប្រសិនបើទំនាក់ទំនងរវាងក្រុមហ៊ុនដែលឧបត្ថម្ភការសិក្សាស្រាវជ្រាវ និងអ្នកស្រាវជ្រាវម្នាក់ត្រូវបានគេសង្ស័យពីការទទួលបានផលប្រយោជន៍ពីការសិក្សានោះ វានឹងនាំឱ្យភាគីទីបីអាចមានការសង្ស័យអំពីអព្យាក្រឹតភាព គោលបំណង និងនីតិវិធីហ្មត់ចត់ផ្នែកវិទ្យាសាស្ត្រដែលត្រូវប្រើក្នុងការសិក្សាអំពីផលិតផល HTPs និងផលប៉ះពាល់សុខភាព។ នោះគឺពួកគេអាចចោទជាសំណួរអំពីលទ្ធភាពដែលទិន្នន័យត្រូវបានគេក្លែងបន្លំ ឬប្រឌិតដើម្បីបង្កើតជាលទ្ធផលសិក្សាស្រាវជ្រាវដោយចេតនាគាំទ្រផលប្រយោជន៍របស់ឧស្សាហកម្មថ្នាំជក់។ ស្ថានភាពបែបនេះហៅថា ទំនាស់ផលប្រយោជន៍ ហើយអ្នកស្រាវជ្រាវត្រូវបានគេតម្រូវឱ្យបើកចំហរទំនាក់ទំនងរបស់គេនឹងផលប្រយោជន៍ដែលអាចមានទំនាក់ទំនងគ្នាដើម្បីប្រាកដថាទំនុកចិត្តសាធារណៈចំពោះការសិក្សាស្រាវជ្រាវនេះនឹងមិនបាត់បង់ឡើយ។*

## ២ ការប្រើប្រាស់គ្រឿងស្រវឹង និងសុខភាព

### ២.១. ផលប៉ះពាល់សុខភាពនៃគ្រឿងស្រវឹង[7]

គ្រឿងស្រវឹង គឺជាថ្នាំសម្រួលសរសៃប្រសាទកណ្តាលហើយមានឥទ្ធិពលបន្ធូរអារម្មណ៍យើងប្រសិនបើទទួលទានក្នុងបរិមាណតិចតួច។ ទោះជាយ៉ាងណាក៏ដោយ មុននឹងទទួលទានគ្រឿងស្រវឹងយើងត្រូវយល់ថា វាមានផលប៉ះពាល់ដល់សុខភាពរយៈពេលខ្លី និងរយៈពេលវែង។ ក្នុងរយៈពេលខ្លី វារារាំងមុខងារខួរក្បាល និងមានឥទ្ធិពលផ្លូវចិត្តដូចជា ការវិនិច្ឆ័យ ហើយមានផលប៉ះពាល់លើរាងកាយដោយបន្ថយចលនារាងកាយ។ លើសពីនេះទៅទៀត ការទទួលទានគ្រឿងស្រវឹងច្រើនក្នុងរយៈពេលខ្លី អាចបណ្តាលឱ្យមាន**ការពុលគ្រឿងស្រវឹងស្រួចស្រាវ (acute alcohol intoxication)** ដែលគំរាមកំហែងដល់អាយុជីវិតដូចជា ក្អួត កម្រិតស្មារតីធ្លាក់ចុះ និងស្ថានភាពផ្លូវដង្ហើមកាន់តែអាក្រក់ទៅៗ។ ទន្ទឹមនឹងនេះដែរ ក្នុងរយៈពេលវែង វានឹងប៉ះពាល់ដល់ថ្លើមដែលទទួលខុសត្រូវក្នុងការកម្ចាត់ជាតិអាល់កុលក៏ដូចជាប៉ះពាល់ដល់រាងកាយទាំងមូល (**រូបទី ១០.២**)។ ឧទាហរណ៍នៃផលប៉ះពាល់រយៈពេលវែងរួមមាន ការកើនឡើងហានិភ័យនៃជំងឺរលាកថ្លើមដែលបណ្តាលមកពីសុរា ជំងឺក្រិនថ្លើម ជំងឺលើសសម្ពាធឈាម ជំងឺមហារីក ជំងឺទឹកនោមផ្អែម និងខូចកោសិកាខួរក្បាល។

**ការញៀនសុរា**




**រូបទី ១០.២៖** ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងលើរាងកាយ

### ២.២. ការញៀនសុរា/ប្រមឹក[8]

ការប្រើប្រាស់គ្រឿងស្រវឹងក្នុងបរិមាណច្រើនរ៉ាំរ៉ៃនឹងវិវឌ្ឍទៅរក**ការញៀនសុរា/ប្រមឹក (dependence on alcohol)** ដែលបណ្តាលឱ្យមានវិបត្តិរ៉ាំរ៉ៃលើមុខងារបញ្ញារបស់ផ្លូវចិត្ត/រាងកាយ។ រោគសញ្ញានៃការញៀនរួមមាន **ការញៀនផ្លូវចិត្ត (psychic dependence)** និង**ការញៀនផ្លូវកាយ (physical dependence)**។ ចំពោះការញៀនផ្លូវចិត្ត (psychic dependence) រោគសញ្ញាដែលអាចលេចឡើងរួមមាន ចំណង់ប្រើប្រាស់គ្រឿងស្រវឹងខ្លាំង ការមិនអាចគ្រប់គ្រងឥរិយាបថប្រើប្រាស់គ្រឿងស្រវឹងបានតាមឆន្ទៈផ្ទាល់ខ្លួន (ឧទាហរណ៍ ពេលវេលា និងបរិមាណ) និងទំនោរក្នុងការទទួលទានគ្រឿងស្រវឹងដើម្បីជំនះនឹងអារម្មណ៍ខកចិត្ត ភាពតានតឹង និងការធ្លាក់ទឹកចិត្តពីភាពតានតឹងប្រចាំថ្ងៃ។ ប្រសិនបើការញៀនផ្លូវចិត្តចេះតែរីកចំរើនទៅមុខបន្ថែមទៀត វានាំឱ្យមានអាកប្បកិរិយាផ្សេងៗដូចជា ការចំណាយពេលភាគច្រើនក្នុងមួយថ្ងៃដើម្បីតែប្រើប្រាស់គ្រឿងស្រវឹង និងមិនអើពើនឹងការសប្បាយផ្សេងក្រៅពីការប្រើប្រាស់គ្រឿងស្រវឹង ហើយមិនតម

ការប្រើប្រាស់គ្រឿងស្រវឹង ទោះបីជាបញ្ហាផ្លូវចិត្ត/រាងកាយកាន់តែធុនធ្ងរទៅៗក៏ដោយ។ ដូច្នេះការញៀនផ្លូវចិត្តគឺជាលក្ខខណ្ឌមួយដែលទម្លាប់ជាប្រចាំបានផ្លាស់ប្តូរទៅតាមចំណង់ខ្លាំងរបស់មនុស្សដើម្បីទទួលបាននូវបទពិសោធន៍អារម្មណ៍រីករាយ និងអារម្មណ៍ល្អម្តងទៀតនៅពេលសុរា**ភ្ញោចលើកោសិកាជំរុញប្រព័ន្ធសរសៃប្រសាទកណ្តាល** ហើយលក្ខខណ្ឌនេះគឺជាធម្មជាតិនៃការញៀន។

ចំពោះការញៀនផ្លូវកាយ (physical dependence) នៅពេលជាតិសុរាបានថយចុះពីក្នុងខ្លួន **រោគសញ្ញាផ្តាច់គ្រឿងស្រវឹង (withdrawal symptoms)** បានលេចឡើងនូវរោគសញ្ញាមួយចំនួនដូចជា ញ័រដៃនិងម្រាមដៃ និងបែកញើស។ អាការៈទាំងនេះអាចបណ្តាលឱ្យមានការប្រើប្រាស់គ្រឿងស្រវឹងនៅកន្លែងធ្វើការ ការធ្លាក់ចុះនៃការអនុវត្តការងារ និងអវត្តមានពីការងារ និងបញ្ហាទំនាក់ទំនងមនុស្សនៅកន្លែងធ្វើការ បណ្តាលឱ្យមានការលំបាកធ្វើការ។ លើសពីនេះទៅទៀត មនុស្សដែលប្រើប្រាស់គ្រឿងស្រវឹងនៅពេលថ្ងៃអាចបំផ្លាញជីវិតគ្រួសាររបស់ពួកគេដោយសារហេតុផលមួយចំនួនរួមមាន ការមិនអាចចូលរួមធ្វើការងារផ្ទះ ឬមើលថែទាំកូនចៅ ការប្រើប្រាស់អំពើហិង្សាលើសមាជិកគ្រួសារ និងការខ្ជីប្រាក់ដើម្បីផឹកស្រា។ ចំពោះករណីនិស្សិតវិញ ពួកគេនឹងមិនអាចបន្តការសិក្សាបានដោយសារមូលហេតុមួយចំនួនដូចជា អវត្តមាន ការសិក្សាខ្សោយ និងការបោះបង់ការសិក្សា។

តាមវិធីនេះ ប្រសិនបើការញៀនផ្លូវចិត្ត និងផ្លូវកាយកើតឡើង វានឹងបំផ្លាញជីវិតសង្គមនៅកន្លែងធ្វើការ គ្រួសារ សាលារៀន និងសហគមន៍របស់អ្នកនោះ។

### ២.៣. ផលប៉ះពាល់សង្គមដែលបណ្តាលមកពីគ្រឿងស្រវឹង[9]

ស្ថានភាពស្រវឹង (ការស្រវឹង) គឺជាស្ថានភាពមួយដែលមានការចុះខ្សោយលើការគ្រប់គ្រងអារម្មណ៍ និងការវិនិច្ឆ័យ។ វាអាចបណ្តាលឱ្យមានបញ្ហាសង្គម និងបញ្ហាជាច្រើនទៀតដូចជា គ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលមកពីការបើកបរពេលស្រវឹង ការដួល និងអាកប្បកិរិយាដែលមានហានិភ័យខ្ពស់ដូចជា អាកប្បកិរិយាផ្លូវភេទដោយមិនបានការពារ និងអាកប្បកិរិយាធ្វើបាបខ្លួនឯង ព្រមទាំងឧបទ្ទវហេតុហិង្សា អំពើហិង្សា/ការបំពានក្នុងគ្រួសារ និងការចូលរួមប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនានា។

## ៣ គ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ និងការប្រើប្រាស់គ្រឿងស្រវឹងដោយអនីតិជន

ការប្រើប្រាស់ថ្នាំជក់ និងគ្រឿងស្រវឹងរបស់អនីតិជនត្រូវបានគេនិយាយថាជាមូលហេតុនាំឱ្យខូចសុខភាពធ្ងន់ធ្ងរ និងអាចបណ្តាលឱ្យញៀន។ នេះក៏ព្រោះតែសរីរាង្គមួយចំនួននៃរាងកាយកំពុងមានការលូតលាស់ហើយមិនទាន់ពេញវ័យ ធ្វើឱ្យសរីរាង្គទាំងនោះងាយនឹងទទួលរងសារជាតិគីមី និងអាល់កុលដែលបង្កគ្រោះថ្នាក់។ ជាពិសេស មនុស្សវ័យក្មេងដែលកំណត់ដោយអង្គការសុខភាពពិភពលោក (WHO) ក្នុងអាយុចន្លោះពី ១០-២៤ឆ្នាំ ជាវ័យឆ្លើយតបនឹងភាពពេញវ័យ/វ័យជំទង់ វាមិនគ្រាន់តែជារយៈពេលមួយដែលផ្លូវភេទលូតលាស់ពេញលេញ និងរាងកាយធំធាត់ទៅជាមនុស្សពេញវ័យនោះទេ ប៉ុន្តែវាក៏ជារយៈពេលអន្តរកាលដើម្បីចម្រើនចិត្តសង្គមទៅជាមនុស្សពេញវ័យដោយសម្រេចបាននូវភារកិច្ចអភិវឌ្ឍន៍សម្រាប់ក្រុមអាយុដែលពាក់ព័ន្ធតាមរយៈការអភិវឌ្ឍខួរក្បាល និងភាពចាស់ទុំ។[10] ទោះបីជាការសម្រេចបាននូវភារកិច្ចអភិវឌ្ឍន៍រាងកាយ បញ្ញា និងភារកិច្ចអភិវឌ្ឍន៍ចិត្តសង្គមត្រូវបានជះឥទ្ធិពលដោយកត្តាផ្សេងទៀតដែលបានរៀបរាប់ក្នុង**ជំពូកទី ៣ និង ទី ១១** ក៏ដោយ ប៉ុន្តែគ្រឿងស្រវឹងមានឥទ្ធិពលលើការអភិវឌ្ឍខួរក្បាលរបស់យុវជន ហើយត្រូវបានគេចាត់ទុកថាមានផលប៉ះពាល់ច្រើនទៀតដល់ការសម្រេចបាននូវភារកិច្ចអភិវឌ្ឍន៍ផងដែរ។

នេះជាមូលហេតុដែលប្រទេសជាច្រើនបានកំណត់អាយុអប្បបរមាសម្រាប់ការប្រើប្រាស់ថ្នាំជក់ និងគ្រឿងស្រវឹង។ នៅប្រទេសជប៉ុន អាយុអប្បបរមាស្របច្បាប់គឺមានអាយុ ២០ឆ្នាំ សម្រាប់សារជាតិទាំងពីរនេះ។ នៅកម្ពុជាអាយុអប្បបរមាសម្រាប់ការប្រើប្រាស់ថ្នាំជក់គឺមានអាយុ ១៨ឆ្នាំ។ ទោះបីជាអាយុអប្បបរមាសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹងមិនទាន់បានបង្កើតឡើងគិតត្រឹមឆ្នាំ២០២០ ក៏ដោយ ក៏មានចលនាទំនោរមួយជំរុញឱ្យកំណត់ត្រឹមអាយុ ២១ឆ្នាំ ដែរ។

## ៤ ការបំពានគ្រឿងញៀន និងសុខភាព

### ៤.១. តើអ្វីទៅជាការបំពានគ្រឿងញៀន?

**ការបំពានគ្រឿងញៀន (drug abuse)** សំដៅលើការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងការប្រើប្រាស់ឱសថក្នុងគោលបំណងផ្សេងក្រៅពីការប្រើប្រាស់សម្រាប់ព្យាបាល។ ថ្នាំដែលត្រូវបានគេប្រើបំពានរួមមាន ថ្នាំជំនួយកម្លាំង កូកាអ៊ីន ថ្នាំសំយោគណាកូទិច MDMA (methylenedioxy-methylamphetamine) ដែលគេស្គាល់ថាជាអេកស្តាស៊ី (Ecstasy) និងហេរ៉ូអ៊ីន (**រូបទី ១០.១**)។ ចំពោះថ្នាំញៀនមានថ្នាំជំនួយប្រព័ន្ធសរសៃប្រសាទកណ្តាល (ថ្នាំលើកកម្លាំង (uppers)) និងថ្នាំបន្ថយប្រព័ន្ធសរសៃប្រសាទកណ្តាល (ថ្នាំបន្ថយកម្លាំង (downers))។ ថ្វីបើមានទិសដៅសកម្មភាពខុសគ្នាក៏ដោយ ប៉ុន្តែទីបំផុតពួកវាបង្កើនសកម្មភាពដូប៉ាមីននៅក្នុងខួរក្បាល រំញោចកោសិកាប្រសាទនៅក្នុង**សំណុំកោសិកាជំរុញ (reward system circuit)** និងបង្កើតភាពរីករាយ។ ថ្នាំទាំងពីរនេះប៉ះពាល់ដល់ខួរក្បាល ហើយអាចបណ្តាលឱ្យស្លាប់ប្រសិនបើប្រើប្រាស់ច្រើនក្នុងពេលតែមួយ។

**តារាងទី ១០.១៖ ប្រភេទថ្នាំញៀន និងឧទាហរណ៍នៃរោគសញ្ញា**

| ប្រភេទ | រោគសញ្ញា |
|---|---|
| ថ្នាំជំនួយកម្លាំង (រំញោចសរសៃប្រសាទកណ្តាល (central nervous excitation)) | បង្ហាញពីសកម្មភាពរំញោចកោសិកាប្រសាទជាច្រើនម៉ោង។ បន្ទាប់មកភាពខ្សោយធ្ងន់ធ្ងរ អស់កម្លាំង និងភាពល្ងិតល្ងៃកើតឡើង។ **ការមើមមាយ (Hallucination)** និង**ការភាន់ភាំង (delusions)** លេចឡើង។ អាចបណ្តាលឱ្យស្លាប់ប្រសិនបើប្រើច្រើន។ទំនងជាឈានទៅ**វិបល្លាសចិត្ត/ឆ្កួតបណ្តាលមកពីសារធាតុញៀន (toxic psychosis)**។ អាចបណ្តាលឱ្យមាន**ការនឹកឃើញឡើងវិញ (flashbacks)** សូម្បីតែបន្ទាប់ពីឈប់ប្រើក៏ដោយ។ |
| កូកាអ៊ីន (រំញោចសរសៃប្រសាទកណ្តាល) | សារធាតុអាល់កាឡូអ៊ីត មាននៅក្នុងកូកាកូឡា។ ផ្តល់នូវបទពិសោធន៍រីករាយខ្លាំង និងអារម្មណ៍ពោរពេញដោយថាមពល។ ការមើមមាយ និងការភាន់ភាំងលេចឡើង។ ការប្រើប្រាស់ច្រើនបណ្តាលឱ្យប្រកាច់ និងពិបាកដកដង្ហើម ហើយអាចបណ្តាលឱ្យស្លាប់។ |
| MDMA (អេកស្តាស៊ី) (រំញោចសរសៃប្រសាទកណ្តាល)  | ប្រភេទថ្នាំញៀនសំយោគ។ ផ្លាស់ប្តូរទស្សនៈ។ បង្កើនអារម្មណ៍ សុខុមាលភាព និងអារម្មណ៍ជិតស្និទ្ធជាមួយអ្នកដទៃ។ ម្យ៉ាងទៀតបង្កើនការគេងមិនលក់ និងភាពមិនស្រួល។ ធ្វើឱ្យមានការប្រែប្រួលចិត្តយ៉ាងខ្លាំង។ ការប្រើប្រាស់ដ៏ច្រើនសន្ទឹកសន្ធាប់បណ្តាលឱ្យឡើងកម្តៅខ្លាំង និងស្លាប់។ |
| ហេរ៉ូអ៊ីន (ធ្វើឱ្យតានតឹងសរសៃប្រសាទកណ្តាល (central nervous depression)) | ថ្នាំញៀនផលិតពីអាភៀន។ បណ្តាលឱ្យមានរោគសញ្ញាផ្តាច់គ្រឿងញៀនធ្ងន់ធ្ងររួមមាន ការឈឺចាប់ធ្ងន់ធ្ងរ គ្រុនញ័រញាក់ ក្អួត និងដួលសន្លប់។ ការប្រើប្រាស់ច្រើន បណ្តាលឱ្យពិបាកដកដង្ហើម និងសន្លប់ បន្ទាប់មកស្លាប់។ |

សូមកត់សម្គាល់ថា ក្រៅពីថ្នាំជក់ គ្រឿងស្រវឹង និងថ្នាំញៀនដែលមានក្នុង**តារាងទី ១០.១** នៅមានថ្នាំញៀន និងសារជាតិគីមីផ្សេងទៀតដែលអាចត្រូវបានគេបំពានដូចជា សារជាតិរំលាយសរីរាង្គដែលងាយនឹងហួត (ឧទាហរណ៍ ទឹកពង្រាវម្រ័ក្សណ៍ខ្មុក និងសារជាតិគីមីតូលុយអែន (toluene) សម្រាប់គំនូរលាបពណ៌ និងការបិទ) និងឱសថ (ឧទាហរណ៍ ថ្នាំបំបាត់ការឈឺចាប់ ថ្នាំបញ្ចុះ ថ្នាំបំបាត់ក្អក ថ្នាំងងុយដេក/ថ្នាំបំបាត់ការថប់បារម្ភ និងថ្នាំផ្ដាសាយ) ដែលអាចរកបានយ៉ាងងាយស្រួល។ ដូច្នេះត្រូវមានការប្រុងប្រយ័ត្ន។

## អត្ថបទដកស្រង់ ១០.៣៖ តើកញ្ឆាគឺស្របច្បាប់ ឬខុសច្បាប់?

*ការរក្សាទុក និងការប្រើប្រាស់កញ្ឆាគឺជាអំពើខុសច្បាប់ជាច្រើនឆ្នាំមកហើយ។ ទោះជាយ៉ាងណាក៏ដោយ វាក៏ជាការពិតទាំងតាមប្រវត្តិសាស្ត្រនិងប្រពៃណីដែលកញ្ឆាត្រូវបានគេប្រើជាឱសថ និងជាអាហារ។*

*ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមានចលនាជំរុញកាន់តែច្រើនឡើងៗនៅក្នុងប្រទេសនិងក្នុងតំបន់មួយចំនួនទាមទារធ្វើឱ្យកញ្ឆាមានភាពស្របច្បាប់។ កញ្ឆា (Cannabis) ត្រូវបានប្រើសម្រាប់គោលបំណងកំសាន្ត វេជ្ជសាស្ត្រ និងឧស្សាហកម្ម។ វាត្រូវបានប្រើដើម្បីភាពរីករាយផ្ទាល់ខ្លួន សម្រាប់ការកំសាន្ត ជាថ្នាំបំបាត់ការឈឺចាប់/ថ្នាំសណ្ដំ និងកែច្នៃសំលៀកបំពាក់ គ្រឿងសម្អាង និងឧស្សាហកម្មម្ហូបអាហារ។ កញ្ឆាសម្រាប់ប្រើក្នុងឧស្សាហកម្មមិនធ្វើឱ្យសប្បាយឡើយ ហើយគេនិយាយថា វាមានហានិភ័យតិចតួចក្នុងការប្រើប្រាស់ជាថ្នាំព្យាបាល។*

*បច្ចុប្បន្ន កញ្ឆាសម្រាប់ប្រើប្រាស់ក្នុងការកម្សាន្តត្រូវបានធ្វើឱ្យស្របច្បាប់ទូទាំងប្រទេសនៅអ៊ុយរូហ្គាយ កាណាដា និងម៉ិកស៊ិកកូ។ នៅសហរដ្ឋអាមេរិក កញ្ឆាត្រូវបានហាមឃាត់ដោយរដ្ឋាភិបាលសហព័ន្ធ ប៉ុន្តែត្រូវបានធ្វើឱ្យស្របច្បាប់ដោយរដ្ឋាភិបាលនៃរដ្ឋមួយចំនួន។ គោលបំណងនៃការធ្វើឱ្យស្របច្បាប់គឺដើម្បីគ្រប់គ្រងឱ្យបានត្រឹមត្រូវដោយកំណត់អាយុស្របច្បាប់សម្រាប់ការប្រើប្រាស់ និងចំនួនអតិបរិមាដែលអាចរក្សាទុក និងដើម្បីកាត់ផ្ដាច់ប្រភពមូលនិធិសម្រាប់អង្គការឧក្រិដ្ឋកម្មដោយការរិតបន្តឹងកញ្ឆាដែលត្រូវបានជួញដូរនៅក្នុងទីផ្សារងងឹត។*

*មានការជជែកគ្នាជាច្រើនចំពោះការគាំទ្រ និងប្រឆាំងនឹងការធ្វើឱ្យកញ្ឆាស្របច្បាប់ ហើយវាត្រូវបានពិភាក្សានៅឯ WHO និងអង្គការសហប្រជាជាតិផងដែរ។ កញ្ឆាត្រូវបានគេនិយាយថាជា**គ្រឿងញៀនបើកមុខ (gateway drug)** (ថ្នាំដែលដើរតួជាផ្លូវបើកមុខ (gateway) ទៅរកការប្រើប្រាស់សារជាតិផ្សេងទៀតដែលមានសារជាតិញៀនខ្លាំងជាងនេះ និងមានប្រតិកម្មមិនល្អដូចជា ថ្នាំជំនួយកម្លាំង ហេរ៉ូអ៊ីន និងកូកាអ៊ីន)។ នេះក៏ព្រោះតែអ្នកដែលមិនពេញចិត្តនឹងកញ្ឆានឹងចាប់ផ្ដើមប្រើថ្នាំដទៃទៀតដើម្បីបង្កើនកម្លាំង។ ការធ្វើឱ្យស្របច្បាប់នៃការប្រើប្រាស់កញ្ឆាអាចបង្កើនឱ្យមានការបំពានថ្នាំដទៃទៀត។*

*គេបានចង្អុលបង្ហាញថា ការប្រើប្រាស់កញ្ឆានឹងប៉ះពាល់ដល់សុខភាពរបស់មនុស្សវ័យក្មេងដូចជា ការវង្វេងស្មារតី ការថយចុះការផ្ដោតអារម្មណ៍ ជំងឺផ្លូវចិត្ត ការក្អួតហួសប្រមាណ និងការញៀន។ ជាពិសេសនៅពេលពេញវ័យ និងវ័យជំទង់វាអាចប៉ះពាល់ដល់ការអភិវឌ្ឍនៃខួរក្បាលផ្នែកខាងមុខក៏ដូចជាសំណុំប្រព័ន្ធប្រសាទ និងរចនាសម្ព័ន្ធសរសៃប្រសាទរបស់អ៊ីប៉ូតាឡាមូស (hippocampus) ដែលមានឥទ្ធិពលអវិជ្ជមានទៅលើមុខងារខួរក្បាលក្នុងការត្រួតពិនិត្យការតាំងស្មារតី ការគិត និងអាកប្បកិរិយាក៏ដូចជាការចងចាំ។ គេគិតថាកាន់តែឆាប់ចាប់ផ្ដើមប្រើកញ្ឆាពេលណាផលប៉ះពាល់កាន់តែធំនៅពេលនោះ។ ដូច្នេះមិនថាកញ្ឆាស្របច្បាប់ ឬខុសច្បាប់ទេ គេមិនគួរប្រើកញ្ឆាក្នុងវ័យដែលខួរក្បាលកំពុងលូតលាស់ ដូចករណីការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជក់អញ្ចឹងដែរ។*[11]

*ចំពោះមនុស្សពេញវ័យដែលរយៈពេលនៃការលូតលាស់របស់ខួរក្បាលបានបញ្ចប់ សង្គមនឹងពិចារណាពីរបៀបត្រូវដោះស្រាយជាមួយការប្រើប្រាស់កញ្ឆាពីជ្រុងទស្សនៈទាំងឡាយ រួមទាំងហានិភ័យ តម្លៃប្រពៃណី/វេជ្ជសាស្ត្រ និងផលប៉ះពាល់នៃនីត្យានុកូលកម្មច្បាប់មកលើសហគមន៍។*

## ៤.២. តើអ្វីជាការញៀនគ្រឿងញៀន?

**ការញៀនគ្រឿងញៀន (Drug dependence)** សំដៅលើស្ថានភាពមួយដែលមនុស្សមិនអាចបោះបង់ការប្រើប្រាស់គ្រឿងញៀនតាមឆន្ទៈផ្ទាល់ខ្លួនដោយសារតែបានប្រើជាយូរមកហើយ ពីព្រោះបើឈប់ប្រើពួកគេនឹងមិនសប្បាយចិត្ត (**រូបទី ១០.៣**)។ ដោយសារតែការទទួលបានថ្នាំញៀនគឺជាអាទិភាពខ្ពស់បំផុតនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ដូច្នេះពួកគេមានការលំបាកក្នុងការត្រឡប់ទៅរកជីវិតធម្មតា ឬព្យាយាមទទួលបានថ្នាំញៀនដោយមិនគិតគេមើលមកខ្លួនយ៉ាងណានោះទេ។ ការសាកល្បងដកបទពិសោធន៍ប្រើថ្នាំញៀនសូម្បីតែមួយដង អាចបណ្តាលឱ្យញៀន ឬអាចរំលឹកជំរុញឱ្យមនុស្សម្នាក់ដែលឈប់ប្រើថ្នាំញៀន ហើយឱ្យចាប់ផ្តើមប្រើម្តងទៀត។

អ្នកញៀនថ្នាំមានចំណង់ខ្លាំងក្នុងការប្រើថ្នាំញៀន នៅពេលវាអស់ឥទ្ធិពលពីក្នុងខ្លួន។ ជាលទ្ធផល ប្រាក់គឺចាំបាច់បំផុតសម្រាប់ពួកគេទិញថ្នាំញៀន ដូច្នេះពួកគេថែមទាំងប្រព្រឹត្តឧក្រិដ្ឋកម្មនានាដូចជា លួចទំនិញក្នុងហាង ប្លន់ និងពេស្យាចារដើម្បីទទួលបានគ្រឿងញៀន។ ពួកគេមិនអាចគ្រប់គ្រងតណ្ហាដោយខ្លួនឯងបានទេ ទោះបីជាពួកគេគិតថាពួកគេមិនចង់ប្រើថ្នាំញៀន ឬចង់បោះបង់វាបន្ទាប់ពីប្រើបានចំនួនខ្លះហើយក៏ដោយ។ ការបញ្ឈប់ការប្រើប្រាស់គ្រឿងញៀនអាចបណ្តាលឱ្យមានរោគសញ្ញាផ្សេងៗរួមមាន ការគេងមិនលក់/ងងុយដេកខ្លាំង ជំងឺធ្លាក់ទឹកចិត្ត ថប់បារម្ភ ការមួម៉ៅ វង្វេងស្មារតី/ការភាន់ភាំង ឈឺសាច់ដុំ/សន្លាក់ ញាក់ប្រកាច់ ហូបច្រើន ខ្សោយ ក្អួតចង្អោរ រាក បែកញើសខុសពីធម្មតា និងរោគសញ្ញាផ្តាច់គ្រឿងញៀន (withdrawal symptoms)។ ការប្រើប្រាស់ថ្នាំញៀនជាប្រចាំបង្កើតភាពធន់ (tolerance) នឹងថ្នាំញៀន និងបង្កើនចំនួនប្រើប្រាស់ចាំបាច់ដើម្បីទទួលបានការសប្បាយ។




**រូបទី ១០.៣៖** វដ្តនៃការញៀនគ្រឿងញៀន

គ្មានថ្នាំ ឬវិធីព្យាបាលជាក់លាក់ណាមួយសម្រាប់ព្យាបាលការញៀនគ្រឿងញៀនទេ។ មធ្យោបាយតែមួយគត់ដែលអាចធ្វើបានគឺបន្តរស់នៅដោយមិនប្រើប្រាស់គ្រឿងញៀន។ ការទទួលបានដំបូន្មានសមស្របពីអ្នកជំនាញ និងការបន្តរស់នៅដោយមិនប្រើប្រាស់គ្រឿងញៀននឹងអាចវិលត្រឡប់ទៅរកជីវិតសង្គមវិញបាន។ នេះហៅថា **ការស្តារឡើងវិញ**។ ដើម្បីសម្រេចបាននូវការស្តារឡើងវិញប្រកបដោយប្រសិទ្ធភាព អ្នកដែលញៀនគ្រឿងស្រវឹង ឬគ្រឿងញៀនខុសច្បាប់ដូចជាថ្នាំជំនួយកម្លាំងគួរតែទទួលស្គាល់ថា ពួកគេមិនអាចគ្រប់គ្រងអាកប្បកិរិយារបស់ពួកគេដោយស្ម័គ្រចិត្តបានទេ និងព្យាយាមដាក់ខ្លួនឱ្យឆ្ងាយពីគ្រឿងញៀនតាមរយៈទំនាក់ទំនងជាមួយមនុស្សដែលធ្លាប់ប្រើប្រាស់គ្រឿងញៀនពីមុនដោយចូលរួមក្នុងក្រុមជួយខ្លួនឯង។

ក្នុងទំនាក់ទំនងនេះ **ក្រុមជួយខ្លួនឯងមួយ**ឈ្មោះ អាល់អាណុន (Al-Anon) ដែលបានចាប់ផ្តើមនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៥១ ហើយចាប់តាំងពីពេលនោះមកបានរីករាលដាលដល់ប្រទេសជាង ១៣០ នៅជុំវិញពិភពលោកបានដាក់ចេញនូវសេចក្តីណែនាំ ១២ជំហាន សម្រាប់**ការជាសះស្បើយឡើងវិញ**ពីការញៀនសុរា។ ជំហានទីមួយគឺ «សេចក្តីប្រកាសគ្មានអំណាច» ដោយនិយាយថា៖ យើងសារភាពថា យើងគ្មានអំណាចលើសគ្រឿងស្រវឹងទេ ដែលគ្រឿងស្រវឹងនេះនឹងធ្វើឱ្យជីវិតយើងបាត់បង់ម្ចាស់ការបាន។ ក្រុមអាល់អាណុន (Al-Anon) មានមូលដ្ឋានមួយនៅទីក្រុងភ្នំពេញ។ ចំណែកឯ**ក្រុមប្រមឹកអនាមិក (Alcoholics Anonymous (AA))** ដែលជាក្រុមជួយខ្លួនឯង បានរៀបចំកិច្ចប្រជុំនៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបាត់ដំបង។ គេរំពឹងថា ក្រុមជួយខ្លួនឯងដែលមានគោលបំណងស្តារឡើងវិញពីការញៀនគ្រឿងញៀនក៏នឹងដើរតួយ៉ាងសកម្មផងដែរនៅក្នុងប្រទេសកម្ពុជា។

**អត្ថបទដកស្រង់ ១០.៤៖ តើភាពធន់ (tolerance) នឹងគ្រឿងញៀនគឺជាអ្វី?**

*ភាពស៊ាំនឹងគ្រឿងញៀនកើតឡើងនៅពេលដែលរាងកាយស៊ាំនឹងគ្រឿងញៀនដោយការប្រើប្រាស់ម្តងហើយម្តងទៀត ដូច្នេះបរិមាណថ្នាំញៀនដែលចាំបាច់ដើម្បីមានប្រសិទ្ធភាពដដែលបានកើនឡើង។ យន្តការមួយនៃយន្តការសរីរៈដែលបង្កើតភាពស៊ាំគឺជាការបញ្ចេញសារជាតិញៀនចេញពីរាងកាយឱ្យបានឆាប់រហ័សដែលជាលទ្ធផលនៃការបង្កើនប្រសិទ្ធភាពការរលាយនៃគ្រឿងញៀន ឬការបង្កើតផ្លូវរំលាយថ្មី (កម្រិតរលាយ)។ លើសពីនេះទៅទៀត ការថយចុះភាពរំញោចនឹងគ្រឿងញៀននៅក្នុងជាលិការាងកាយក៏អាចកើនឡើងផងដែរ (កម្រិតជាលិការាងកាយ)។*

## ៤.៣. ការរីករាលដាលនៃគ្រឿងញៀននៅតំបន់ប៉ាស៊ីហ្វិកខាងលិច[12]

**តំបន់ត្រីកោណមាស (The Golden Triangle)** ដែលជាតំបន់គ្របដណ្តប់ប្រទេសភូមា ថៃ និងឡាវ ត្រូវបានគេស្គាល់ថាជាតំបន់ផលិត/ចែកចាយអាភៀន (**រូបទី ១០.៤**)។ ជាពិសេសប្រទេសភូមា ល្បីល្បាញដោយសារចំការអាភៀនច្រើនដ៏សន្ធឹកសន្ធាប់។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រភេទ**គ្រឿងញៀនណាកូទិច**ដែលផលិតនៅតំបន់ត្រីកោណមាសនេះបានផ្លាស់ប្តូររូបរាងពីអាភៀននិងហេរ៉ូអ៊ីនដែលផលិតពីរុក្ខជាតិអាភៀនផប៉ពី (poppy) ទៅជាថ្នាំជំនួយកម្លាំង (ណាកូទិចសំយោគវិញ)។ ថ្នាំជំនួយកម្លាំង មិនត្រឹមតែត្រូវបានគេប្រើប្រាស់នៅក្នុងប្រទេសភូមា ថៃ និងឡាវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរត់ពន្ធចូលទៅក្នុងប្រទេសជុំវិញដូចជាកម្ពុជា វៀតណាម បង់ក្លាដែស ឥណ្ឌា និងចិន។ លើសពីនេះទៅទៀត គ្រឿងញៀនទាំងនេះបានរាលដាលពាសពេញតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូលមានប្រទេសដូចជា ជប៉ុន កូរ៉េ តៃវ៉ាន់ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន អូស្ត្រាលី និងនូវែលហ្សេឡង់។ ក្រៅពីតំបន់ត្រីកោណមាស នៅមានតំបន់ជាច្រើននៅជុំវិញពិភពលោកដែលផលិតណាកូទិច។ គ្រឿងញៀនរួមទាំងណាកូទិចដែលត្រូវបានរត់ពន្ធឆ្លងកាត់ព្រំដែនកំពុងគំរាមកំហែងដល់សុខភាពមនុស្សនៅជុំវិញពិភពលោក។




**រូបទី ១០.៤៖** តំបន់ត្រីកោណមាស

**អត្ថបទដកស្រង់ ១០.៥៖ តើគ្រឿងញៀនណាកូទិចជាអ្វី?**

*គ្រឿងញៀនណាកូទិច (Narcotic drugs) ពីដំបូងសំដៅទៅលើសារជាតិផ្សេងៗដែលធ្វើឱ្យអារម្មណ៍ស្ពឹក ដើម្បីកាត់បន្ថយការឈឺចាប់។ សព្វថ្ងៃនេះ អាភៀន អាភៀនក្លាយ និងថ្នាំបំបាត់ការឈឺចាប់ដែលសំយោគចេញពីអាភៀនត្រូវបានគេហៅថា គ្រឿងញៀនណាកូទិច។ ទោះជាយ៉ាងណាក៏ដោយ ដោយសារគ្រឿងញៀនញៀនណាកូទិចអាចសំដៅលើគ្រឿងញៀនដទៃទៀត គេហៅវាថា អូព្យូអ៊ីដ (opioids) សម្រាប់ការចាត់ថ្នាក់ប្រភេទរបស់វា។ អូព្យូអ៊ីដ (Opioids) គឺជាគ្រឿងញៀនមួយប្រភេទរួមមាន ហេរ៉ូអ៊ីន ម៉ូហ្វីន និងកូដេអ៊ីន។*[13]

## ៥ ការរីករាលដាលនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀននៅប្រទេសកម្ពុជា

### ៥.១. ការប្រើប្រាស់ថ្នាំជក់នៅប្រទេសកម្ពុជា

របាយការណ៍របស់**អង្គការសុខភាពពិភពលោក (WHO)** ស្តីពីការរីករាលដាលថ្នាំជក់សកលឆ្នាំ២០១៩ របាយការណ៍ប្រចាំប្រទេសកម្ពុជា[14] បង្ហាញថា ការស្ទង់មតិចុងក្រោយស្តីពីការប្រើប្រាស់ថ្នាំជក់នៅកម្ពុជាគឺ ការស្ទង់មតិជាតិស្តីពីថ្នាំជក់សម្រាប់មនុស្សពេញវ័យនៅកម្ពុជា (២០១៤)[15] និងការស្ទង់មតិសកលស្តីពីថ្នាំជក់សម្រាប់យុវជន (២០១៦)។[16] អ្វីដែលត្រូវបានការពណ៌នាខាងក្រោមគឺជាស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ថ្នាំជក់នៅកម្ពុជាដោយផ្អែកលើរបាយការណ៍ទាំងនេះ។

យោងតាមការស្ទង់មតិជាតិស្តីពីថ្នាំជក់សម្រាប់មនុស្សពេញវ័យនៃប្រទេសកម្ពុជា (២០១៤) គិតត្រឹមឆ្នាំ២០១៤ ប្រជាជនកម្ពុជា ២២% (ប្រមាណ ១,៦៨លាននាក់) ដែលមានអាយុចាប់ពី ១៥ឆ្នាំឡើងទៅ ប្រើប្រាស់ផលិតផលថ្នាំជក់ ដោយមានអត្រាប្រេវ៉ាឡង់នៃ**ការជក់បារី**គឺ ១៦,៦% សម្រាប់ក្រុមទាំងមូល ៣២,៩% សម្រាប់បុរស និង ២,៤% សម្រាប់ស្ត្រី។ ទន្ទឹមនឹងនេះ អត្រាប្រើប្រាស់**ថ្នាំជក់គ្មានផ្សែង (ថ្នាំចុក/ថ្នាំទំពារ)** ក្នុងចំណោមមនុស្សដែលមានអាយុចាប់ពី ១៥ឆ្នាំឡើងទៅគឺ ០,៨% ចំពោះបុរស និងខ្ពស់ជាង ៨,៦% ចំពោះស្ត្រី។[15] គ្រឿងផ្សំដែលត្រូវប្រើសម្រាប់ធ្វើជាថ្នាំជក់គ្មានផ្សែងរួមមាន ស្លា ម្លូដែលភាគច្រើនសំដៅដល់ការលាយចូលគ្នារវាងស្លានិងកំបោររស់រុំនឹងស្លឹកម្លូ (**រូបទី ១០.៥**)។ គេបានបង្ហាញថា ស្ត្រីម្នាក់ក្នុងចំណោម ១០នាក់ នៅតាមជនបទប្រើថ្នាំជក់គ្មានផ្សែងប្រភេទនេះដោយអត្រាប្រើប្រាស់កើនឡើងតាមអាយុ។[15] ថ្វីបើថ្នាំជក់គ្មានផ្សែងជាវប្បធម៌/ប្រពៃណីត្រូវបានគេចាត់ទុកជាថ្នាំបុរាណក៏ដោយក៏វាត្រូវបានគេចាត់ទុកថាមានផលអាក្រក់ (ហានិភ័យនៃជំងឺមហារីកមាត់) លើរាងកាយមនុស្សដូចជាការជក់បារីអញ្ចឹងដែរ។



**រូបទី ១០.៥៖** ស្លាម្លូ (ថ្នាំចុក)

ទាក់ទងនឹងការប្រើប្រាស់ផលិតផលថ្នាំជក់ដោយក្រុមមនុស្សវ័យក្មេង ៦,៤% អាយុពី ១៣-១៥ឆ្នាំ បានប្រើប្រាស់ផលិតផលថ្នាំជក់ (ថ្នាំជក់មានផ្សែងនិង/ឬគ្មានផ្សែង) ដោយបច្ចុប្បន្នមាន ២,៤% ប្រើប្រាស់ផលិតផលថ្នាំជក់។[16] វាមានការផ្សាយពាណិជ្ជកម្មជាច្រើននៅក្នុងទីក្រុងដែលលើកទឹកចិត្តមនុស្សឱ្យជក់បារី ហើយប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញពីទិដ្ឋភាពនៃការប្រើប្រាស់ថ្នាំជក់។ លើសពីនេះទៅទៀត តម្លៃថ្នាំជក់ថោកអាចជាហេតុផលមួយទៀតដែលក្រុមមនុស្សវ័យក្មេងអាចចាប់ផ្តើមជក់បានយ៉ាងងាយស្រួល។

ម៉្យាងទៀតមានមនុស្សពេញវ័យជាច្រើនគិតថា ការប្រើប្រាស់ថ្នាំជក់អាចបង្កឱ្យមានជំងឺបេះដូង និងមហារីកសួត និងគាំទ្រការរឹតត្បិតការប្រើប្រាស់ថ្នាំជក់នៅកន្លែងសាធារណៈ និងបង្កើនពន្ធថ្នាំជក់។ ដូចមនុស្សពេញវ័យដែរកុមារក៏យល់ពីផលប៉ះពាល់នៃថ្នាំជក់ចំពោះសុខភាពរបស់ពួកគេ និងសារៈសំខាន់នៃការរឹតត្បិតការប្រើប្រាស់ថ្នាំជក់នៅកន្លែងសាធារណៈ (**តារាងទី ១០.២**)។[16]

**តារាងទី ១០.២៖ ចំណេះដឹង និងអាកប្បកិរិយារបស់សិស្សចំពោះការជក់បារី**

| ចំណេះដឹង និងឥរិយាបថ | % |
|---|---|
| សិស្សដែលពិតជាគិតថា ការជក់បារីរបស់អ្នកដទៃបង្គ្រោះថ្នាក់ដល់ពួកគេ | 78.5% |
| សិស្សដែលគាំទ្រការហាមឃាត់ការជក់បារីនៅទីសាធារណៈដែលបិទជិត | 60.7% |
| សិស្សដែលគាំទ្រការហាមឃាត់ការជក់បារីនៅកន្លែងសាធារណៈខាងក្រៅ | 60.8% |

ប្រភព៖ WHO. Global Youth Tobacco Survey Cambodia 2016[16]

## ៥.២. ការប្រើប្រាស់គ្រឿងស្រវឹងនៅប្រទេសកម្ពុជា

ចំពោះប្រជាជនកម្ពុជា ការប្រើប្រាស់គ្រឿងស្រវឹងប្រចាំឆ្នាំរបស់មនុស្សម្នាក់ៗក្នុងចំណោមអ្នកផឹកដែលមានអាយុចាប់ពី ១៥ឆ្នាំឡើងទៅគឺ ២១,៧លីត្រ (**តារាងទី ១០.៣**)។[17] នេះតំណាងឱ្យការប្រើប្រាស់ដែលបានបំប្លែងទៅជាស្រាសុទ្ធ ការប្រើប្រាស់ប្រចាំឆ្នាំស្មើនឹង ៤៣៤លីត្រ ក្នុងករណីស្រាបៀរដែលមានជាតិអាល់កុល ៥%។

**តារាងទី ១០.៣៖ ការប្រើប្រាស់គ្រឿងស្រវឹងសរុបក្នុងមនុស្សម្នាក់ គិតតែក្នុងករណីអ្នកផឹក (គិតជាលីត្រអាល់កុលសុទ្ធ)**

| កម្ពុជា | ជប៉ុន | ថៃ | ភូមា | វៀតណាម | ឡាវ |
|---|---|---|---|---|---|
| 21.7 | 14.1 | 20.3 | 17.6 | 22.8 | 25.9 |

ប្រភព៖ WHO. Global Status Report on Alcohol and Health 2018[17]

យោងតាមលទ្ធផលនៃការស្ទង់មតិសកលស្តីពីសុខភាពសិស្សតាមសាលារៀនឆ្នាំ២០១៣ (Global School-based Student Health Survey (GSHS), 2013)[18] ក្នុងចំណោមសិស្សប្រុស និងសិស្សស្រីដែលមានអាយុពី ១៣-១៧ឆ្នាំ ភាគរយនៃអ្នកដែលផឹកគ្រឿងស្រវឹងយ៉ាងហោចណាស់មួយកែវក្នុងរយៈពេល ៣០ថ្ងៃចុងក្រោយគឺ សិស្សប្រុសមាន ១២,៥% (N=១២៥០) និងសិស្សស្រីមាន ៤,៤% (N=១៥២៦)។ ភាគរយនៃអ្នកដែលធ្លាប់ផឹកគ្រឿងស្រវឹងគឺសិស្សប្រុសមាន ២៨,៧% និងសិស្សស្រីមាន ១២,៧%។ ភាគរយនៃអ្នកដែលមានបញ្ហាដែលបណ្តាលមកពីការផឹកគ្រឿងស្រវឹងរួមទាំងបញ្ហាជាមួយសមាជិកគ្រួសារ ឬមិត្តភក្តិ អវត្តមានពីសាលារៀន និងការឈ្លោះវាយតប់គ្នាគឺសិស្សប្រុសមាន ២,៦% និងសិស្សស្រីមាន ១,៦%។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានកម្រិតអប្បបរមានៃការរឹតត្បិតផ្នែកច្បាប់លើគ្រឿងស្រវឹងដោយមិនកំណត់អាយុអប្បបរមាសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹង ឬការដាក់កំហិតលើការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង។ ថ្វីបើមានការកំណត់កំហាប់ជាតិអាល់កុលក្នុងឈាមសម្រាប់ការបើកបរក៏ដោយ ប៉ុន្តែគ្មានភាពជាក់លាក់ថា តើការបង្ក្រាបចំពោះការបើកបរពេលស្រវឹងត្រូវបានអនុវត្តត្រឹមត្រូវដោយផ្អែកលើមូលដ្ឋានកំណត់ដែរ ឬយ៉ាងណា។ វាក៏មានករណីខ្លះដែរ ដែលការបង់ពន្ធរបស់ក្រុមហ៊ុនផលិតក្រៅផ្លូវការត្រូវបានគេចវេសដោយសារតែការរឹតបន្តឹងមានភាពធូរលុង(**តារាងទី ១០.៤**)។[19]

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ មានចលនាមួយទាមទារឱ្យកែតម្រូវច្បាប់នេះសារឡើងវិញ។ ការរឹតត្បិតលទ្ធភាពនៃការប្រើប្រាស់គ្រឿងស្រវឹងមិនត្រឹមតែបង្ការការខូចសុខភាព និងការញៀនប៉ុណ្ណោះទេប៉ុន្តែថែមទាំងទប់ស្កាត់ឧបទ្ទវហេតុ និងគ្រោះថ្នាក់រួមមាន ការបើកបរពេលស្រវឹង ការឈ្លោះវាយតប់គ្នា អំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ។

**តារាងទី ១០.៤៖ បញ្ហាក្នុងការរឹតបន្តឹងច្បាប់លើគ្រឿងស្រវឹង**

១. ការកំណត់អាយុមិនគ្រប់គ្រាន់
២. ការដាក់កំហិតមិនគ្រប់គ្រាន់លើម៉ោងលក់គ្រឿងស្រវឹង
៣. ការកំណត់កំហាប់ជាតិអាល់កុលក្នុងឈាមពេលបើកបរមានភាពធូររលុង
៤. ការដាក់កម្រិតលើការផ្សាយពាណិជ្ជកម្មមិនគ្រប់គ្រាន់
៥. ខ្វះច្បាប់គ្រប់គ្រងអ្នកឧបត្ថម្ភកម្មវិធី និងការផ្សព្វផ្សាយការលក់
៦. ការមិនដាក់បញ្ចូលសារព្រមានលើកេស ឬកញ្ចប់ និងការផ្សាយពាណិជ្ជកម្ម

ប្រភព៖ មូលនិធិអាស៊ី (២០១៦)[19]

**អត្ថបទដកស្រង់ ១០.៦៖ ការស្ទង់មតិយុវជនដែលមានហានិភ័យបំផុត (Most at Risk Young People (MARYP)) នៅតំបន់ក្តៅ ( hot spots )** [20]

*ការស្ទង់មតិយុវជនដែលងាយរងគ្រោះពីសង្គមអាយុពី ១០-២៤ឆ្នាំ ដែលពាក់ព័ន្ធនឹងអាកប្បកិរិយាដែលមានហានិភ័យខ្ពស់ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១០។ គោលបំណងនៃការស្ទង់មតិនេះគឺមិនមែនដើម្បីស្វែងយល់ពីស្ថានភាពរបស់យុវជនទូទៅនោះទេ ប៉ុន្តែដើម្បីកំណត់ពីអាកប្បកិរិយា និងស្មារតីរបស់យុវជនដែលមានហានិភ័យបំផុត ទាក់ទងនឹងគ្រឿងស្រវឹង គ្រឿងញៀន និងការរួមភេទ ហើយប្រមូលផ្តុំនៅតាម «តំបន់ក្តៅ ( hot spots )» ( ឧទាហរណ៍ បារ ហាងខារ៉ាអូខេ ហាងម៉ាស្សា និងមជ្ឈមណ្ឌលហ្គេម ) នៅក្នុងរដ្ឋចំនួន ៨ ដែលមានអាកប្បកិរិយាហានិភ័យខ្ពស់ចំពោះការឆ្លងមេរោគអេដស៍ដែលបានរីករាលដាល។*

*ក្នុងចំណោមអ្នកដែលមានអាយុពី ១០-១៩ឆ្នាំ ដែលត្រូវបានស្ទង់មតិ បុរស ៨១,៤% និងស្ត្រី ៥៧,៦% បានឆ្លើយថា ពួកគេធ្លាប់ប្រើប្រាស់គ្រឿងស្រវឹង។ ក្នុងចំណោមមនុស្សទាំងនេះ ២,៣% នៃបុរស ( ១,៩% នៃចំនួនសរុប ) និងស្ត្រី ១៨% ( ១០,៤% នៃចំនួនសរុប ) ដឹងថា ការប្រើប្រាស់គ្រឿងស្រវឹងរបស់ពួកគេមានកម្រិតខ្ពស់។ ការយល់ដឹងអំពីការប្រើប្រាស់គ្រឿងស្រវឹងខ្ពស់មានភាពខុសប្លែកគ្នារវាងភេទហើយភាពខុសគ្នាកាន់តែខ្លាំងចំពោះក្រុមអាយុពី ២០-២៤ឆ្នាំ។ នេះប្រហែលជាដោយសារតែយុវនារីដែលធ្វើការនៅបារ ខារ៉ាអូខេ និងក្លឹបរាត្រីមានឱកាសច្រើនក្នុងការប្រើប្រាស់គ្រឿងស្រវឹងជាមួយអតិថិជនរបស់ពួកគេ។*

*ការស្ទង់មតិបង្ហាញថា មូលហេតុនៃការប្រើប្រាស់គ្រឿងស្រវឹងដោយយុវជនដែលមានហានិភ័យបំផុតរួមមានការចង់ដឹងចង់ឃើញនូវអ្វីដែលថ្មី ការចង់ជំនះភាពតានតឹងចិត្តនិងការធ្លាក់ទឹកចិត្ត ការចង់ទប់ទល់នឹងព្រឹត្តិការណ៍នៅសាលារៀន ( ឧទាហរណ៍ ការបរាជ័យក្នុងការប្រឡង សម្ពាធពីកាលបរិច្ឆេទផុតកំណត់កិច្ចការ ការឈ្លោះប្រកែកគ្នាជាមួយមិត្តភក្តិ ទំនាក់ទំនងស្នេហា ) ការប្រើប្រាស់គ្រឿងស្រវឹងរបស់សមាជិកក្នុងគ្រួសារ ការជួបជាញឹកញាប់នឹងការប្រើប្រាស់គ្រឿងស្រវឹង/ការប្រើប្រាស់គ្រឿងញៀន/ការប្រើប្រាស់ថ្នាំជក់នៅក្នុងមូលដ្ឋានឬសហគមន៍ ការមិនចង់ឱ្យគេបណ្តេញចេញពីក្រុមមិត្តភក្តិ និងហេតុផលចិត្តសង្គមដូចជាការរងសម្ពាធពីមិត្តភក្តិជាដើម។ ការស្ទង់មតិក៏បង្ហាញផងដែរថា តាមទស្សនៈរបស់យុវជនក្រុមនេះដែលយល់ឃើញថាការអប់រំមិនធានាភាពជោគជ័យក្នុងជីវិតនោះទេ ហើយរូបរាងទាន់សម័យគឺមានសារៈសំខាន់ខ្លាំងណាស់ដោយគ្រឿងស្រវឹងត្រូវបានគេមើលឃើញថាជាអាកប្បកិរិយាទាន់សម័យ។*

## ៥.៣. ការប្រើប្រាស់គ្រឿងញៀននៅប្រទេសកម្ពុជា

ដូចបានពិពណ៌នានៅក្នុង «ការរីករាលដាលនៃគ្រឿងញៀននៅតំបន់ប៉ាស៊ីហ្វិកខាងលិច» នៃជំពូកនេះ ប្រទេសកម្ពុជាមិនត្រូវបានរាប់បញ្ចូលក្នុងតំបន់ត្រីកោណមាសនោះទេ ប៉ុន្តែគ្រឿងញៀនចូលមកក្នុងប្រទេសពីការជួញដូរពីប្រទេសដែលនៅជិតខាងដូចជា ថៃ ឡាវ និងវៀតណាម។ នៅប្រទេសកម្ពុជាថ្នាំជំនួយកម្លាំង ( គ្រាប់មេតំហ្វេតាមីន និងមេតំហ្វេតាមីនគ្រីស្តាល់ ) អេចស្តាស៊ី ហេរ៉ូអ៊ីន និងខេតាមីនត្រូវបានប្រើប្រាស់ដោយខុសច្បាប់។ ចាប់តាំងពីឆ្នាំ២០១៧ ដោយសារតែការចាប់ផ្តើម**យុទ្ធនាការប្រឆាំងគ្រឿងញៀន**ដោយរដ្ឋាភិបាល ការបង្ក្រាបគ្រឿងញៀនត្រូវបានបង្កើន ហើយចំនួនដែលរឹបអូសបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ( **តារាងទី ១០.៥** )។[21] ទោះជាយ៉ាងណាក៏ដោយ ការញៀនគ្រឿងញៀននៅតែជាបញ្ហាប្រឈមមួយ។ គេនិយាយថា មនុស្សសរុបជាង ២០ ០០០នាក់ កំពុងស្ថិតនៅក្នុងមណ្ឌលស្តារនីតិសម្បទាក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល។ ការប្រើប្រាស់គ្រឿងញៀនកំពុងរីករាលដាលជាពិសេសក្នុងចំណោមមនុស្សវ័យក្មេងហើយមនុស្សចំនួន ៤៩% ដែលចូលក្នុងមណ្ឌលព្យាបាលគ្រឿងញៀនត្រូវបានគេរាយការណ៍ថាជាមនុស្សវ័យក្មេងដែលមានអាយុចាប់ពី ១៨-២៥ ឆ្នាំ ( **រូបទី ១០.៦** )។[21,22]

**តារាងទី ១០.៥៖ ការរឹបអូសគ្រឿងញៀនតាមប្រភេទនីមួយៗនៅកម្ពុជា 2014-2019 -UNODC 2020**

| ប្រភេទគ្រឿងញៀន | ឯកតា | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| គ្រាប់ថ្នាំមេតំហ្វេតាមីន (Methamphetamine tablets) | tablets | 87,000 | 265,760 | 490,689 | 371,556 | 77,000 | 483,402 |
| មេតំហ្វេតាមីនគ្រីស្តាល់/ម៉ាទឹកកក (Crtstalline methamphetamine) | kg | 29 | 72.9 | 66.3 | 80.1 | 306.6 | 384.9 |
| អេកស្តាស៊ី (Ecstacy) | tablets | 10,533 | 70 | 5,509 | 83,533 | 599,200 | 382,728 |
| កញ្ឆា (Cannabis herb) | kg | 19.9 | 1,511.5 | 37 | 116.3 | 74.0 | 102.8 |
| កូកាអ៊ីន (Cocaine) | kg | 7.9 | 5.3 | 14 | 12.8 | 5.4 | 61.1 |
| ហេរ៉ូអ៊ីន (Heroin) | kg | 1.8 | 2.5 | 6.2 | 22.5 | 1.3 | 47.9 |
| ខេតាមីន (Ketamine) | kg | 0.0 | 0.1 | 1.1 | 6.3 | 36.3 | 33.1 |

ប្រភព៖ United Nations Office on Drugs and Crime (UNODC) : Synthetic Drugs in East and South-East Asia: Latest developments and challenges. 2020




ប្រភព៖ UNODC: Synthetic Drugs in East and South-East Asia: Latest developments and challenges. 2020

**រូបទី ១០.៦៖** មណ្ឌលទទួលព្យាបាលគ្រឿងញៀននៅកម្ពុជាតាមក្រុមអាយុ - UNODC ២០២០

គ្រឿងញៀនក៏ជាការគំរាមកំហែងដល់កុមារផងដែរ។ ការស្ទង់មតិរបស់កុមារអាយុចន្លោះពី ១៣-១៨ឆ្នាំ[23] បានបង្ហាញថា កុមារចំនួន ១៥,៩% បានឃើញការជួញដូរគ្រឿងញៀននៅក្នុងតំបន់ដែលពួកគេរស់នៅ។ ភាគរយនៃកុមារដែលបានឃើញនរណាម្នាក់ប្រើប្រាស់គ្រឿងញៀនមានចំនួន ១៨,៩% ក្នុងនោះ ៧០,២% និយាយថា ពួកគេបានឃើញនៅកន្លែងដែលពួកគេរស់នៅ។ ភាគរយនៃកុមារដែលបានទទួលគ្រឿងញៀនពីមិត្តភក្តិ ឬអ្នកជិតខាងមាន ៤,៩%។ គេបានរាយការណ៍ថា កុមារដែលបានឃើញការជួញដូរគ្រឿងញៀននៅក្នុងតំបន់ដែលពួកគេរស់នៅ និងអ្នកដែលត្រូវបានមិត្តភក្តិ ឬអ្នកជិតខាងផ្តល់ថ្នាំញៀនហាក់ដូចជា អន្ទះសារនៅពេលដែលនៅផ្ទះតែម្នាក់ឯង ឬមិនចូលចិត្តទៅសាលារៀន ឬកន្លែងសាធារណៈ។ ដើម្បីឱ្យកុមារលូតលាស់ និងអភិវឌ្ឍប្រកបដោយសុខភាពល្អ សំខាន់ត្រូវមានកម្មវិធីបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនសំដៅ**បង្កើតសហគមន៍ដែលមានសុវត្ថិភាព**ដែលបទដ្ឋានសង្គមត្រូវបានបង្កើតឡើងដើម្បីបង្កើនស្មារតីសាមគ្គីភាពក្នុងសហគមន៍ និងបដិសេធការប្រើប្រាស់គ្រឿងញៀន។ ដើម្បីសម្រេចបានកិច្ចការនេះ ចាំបាច់ត្រូវកែលម្អបរិយាកាសសេដ្ឋកិច្ចសង្គម និងវប្បធម៌របស់សហគមន៍ដូចជា ភាពក្រីក្រ ភាពអត់ការងារធ្វើ ឬកង្វះការងារ ភាពចលាចលក្នុងសង្គម និងមានហាងលក់គ្រឿងស្រវឹង និងថ្នាំជក់ច្រើន។

## ៥.៤. កត្តាចិត្តសាស្ត្រ/សង្គមទាក់ទងនឹងការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀន

**អត្ថបទដកស្រង់៖** *ដូចដែលបានជ្រាបរួចមកហើយនៅក្នុងផ្នែកនៃការស្វង់មតិយុវជនប្រឈមបំផុត (Most at Risk Young People) នៅកន្លែងគ្រោះថ្នាក់នានា កត្តាដែលអាចបង្កឱ្យយុវជនប្រឈមខ្ពស់ចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀនគឺបណ្តាលមកពីចម្ងល់នៃការចង់ដឹងចង់ឃើញដូចជា «ខ្ញុំគ្រាន់តែចង់សាកល្បងអ្វីដែលថ្មី» ឬ «ខ្ញុំគ្រាន់តែសាកល្បងលេង» ឬចំណាប់អារម្មណ៍ក្រោមឥទ្ធិពលនៃសមាជិកគ្រួសារ/មិត្តភក្តិរបស់ពួកគេ ឬការផ្សាយពាណិជ្ជកម្មដូចជា «ពួកគេមើលទៅស្រស់ស្អាត» «វាមើលទៅគួរឱ្យឆ្ងាញ់» និង «ខ្ញុំបានឃើញការផ្សព្វផ្សាយពាណិជ្ជកម្ម»។ យុវជនខ្លះចាប់ផ្តើមប្រើប្រាស់របស់ទាំងនោះនៅពេលដែលពួកគេធ្លាក់ទឹកចិត្តដោយសារតែមានបញ្ហាជាមួយមិត្តភក្តិ មនុស្សជាទីស្រឡាញ់ ឬសមាជិកគ្រួសារ។ បន្ថែមពីលើនេះ ការអញ្ជើញ ឬដាក់សម្ពាធពីមិត្តភក្តិជាកត្តាមួយទៀតដែរ។ យុវជនជាច្រើនមានការព្រួយបារម្ភថា ពួកគេអាចត្រូវកាត់ផ្តាច់ចេញពីក្រុម ប្រសិនបើបដិសេធការអញ្ជើញពីមិត្តភក្តិរបស់ពួកគេ ហើយត្រូវទទួលយកការអញ្ជើញនោះដើម្បីរក្សាចំណងមិត្តភាព។ ករណីដែលបានរៀបរាប់ទាំងអស់នេះពួកគេមានបំណងគ្រាន់តែសាកល្បងមួយលើកប៉ុណ្ណោះ ប៉ុន្តែក្រោយមកក៏ក្លាយជាទម្លាប់ប្រើប្រាស់ជាប្រចាំ។[20,24]*

*គេបានគិតថា វាមានទំនាក់ទំនងរវាងការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជក់៖ បុរសដែលជក់បារីច្រើនតែប្រើប្រាស់គ្រឿងស្រវឹងជាងបុរសដែលមិនជក់បារី។ ទោះបីជាទំនាក់ទំនងមិនច្បាស់លាស់ដូចបុរសក៏ដោយ ស្ត្រីដែលប្រើថ្នាំចុកត្រូវបានគេនិយាយថាទំនងជាងាយប្រើប្រាស់គ្រឿងស្រវឹងដែរ។*

*ដើម្បីផ្លាស់ប្តូរឥរិយាបថប្រឈមដែលទាក់ទងគ្នា ពោលគឺការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ ថ្នាំញៀន និងសកម្មភាពផ្លូវភេទដោយគ្មានការការពារ វាមានការចាំបាច់ក្នុងការកាត់បន្ថយភាពតានតឹងក្នុងសង្គមដែលពួកគេកំពុងជួបប្រទះព្រមទាំងអនុវត្តជាប្រចាំនូវការអប់រំសុខភាព និងគោលនយោបាយសង្គមដើម្បីផ្លាស់ប្តូរគុណតម្លៃរបស់ពួកគេ។*

### អត្ថបទដកស្រង់ ១០.៧៖ យុទ្ធសាស្ត្រសកលលើថ្នាំជក់ និងគ្រឿងស្រវឹង (រូបទី ១០.៧)

*ចំពោះយុទ្ធសាស្ត្រថ្នាំជក់សកល* ***ក្របខ័ណ្ឌអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ (the Framework Convention on Tobacco Control)***[5] *ត្រូវបានអនុម័តនៅឯសន្និបាតសុខភាពពិភពលោកលើកទី ៥៦ ក្នុងឆ្នាំ២០០៣ និងចូលជាធរមាននៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៥។ គោលបំណងនៃអនុសញ្ញានេះគឺដើម្បីការពារជំនាន់មនុស្សបច្ចុប្បន្ន និងអនាគតពីផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់។ល។ ដើម្បីសម្រេចបានគោលបំណងនេះ អនុសញ្ញាបានដាក់បញ្ចូល «ការការពារពីការប៉ះពាល់នឹងផ្សែងថ្នាំជក់» «ត្រូវប្រាកដថា ការវេចខ្ចប់ និងការដាក់ស្លាកផលិតផលថ្នាំជក់ជំរុញផ្សព្វផ្សាយផលិតផលថ្នាំជក់តាមមធ្យោបាយណាមួយក៏ដោយដែលមិនពិត បំភាន់ បោកបញ្ឆោត ឬទំនងជាបង្កើតចំណាប់អារម្មណ៍ខុសឆ្គង និងការព្រមានអំពីសុខភាពត្រូវមានមិនតិចជាង ៣០% នៃតំបន់បង្ហាញលើកញ្ចប់» «ការហាមឃាត់ ឬការរឹតត្បិតដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយលើការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយ និងការឧបត្ថម្ភរបស់ថ្នាំជក់» «ចាត់វិធានការលុបបំបាត់ពាណិជ្ជកម្មខុសច្បាប់លើផលិតផលថ្នាំជក់ដោយតម្រូវឱ្យមានខ្នាតកញ្ចប់ និងកញ្ចប់ផលិតផលថ្នាំជក់ដើម្បីអនុវត្តការសម្គាល់ប្រកបដោយប្រសិទ្ធភាពដែលបង្ហាញពីទិសដៅចុងក្រោយ» «ការអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាពដើម្បីហាមឃាត់ការលក់ផលិតផលថ្នាំជក់ដល់អនីតិជន» «ការបង្កើតសន្និសីទរបស់ភាគីដែលស្ថិតក្រោមការត្រួតពិនិត្យជាប្រចាំនូវការអនុវត្តអនុសញ្ញា និងការសម្រេចចិត្តដែលចាំបាច់ដើម្បីលើកកម្ពស់ការអនុវត្តប្រកបដោយប្រសិទ្ធភាព» ហើយ «ភាគីនីមួយៗត្រូវបញ្ជូនរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញានេះទៅសន្និសីទភាគីតាមកាលកំណត់»។*[5]

*ទន្ទឹមនឹងនេះ «យុទ្ធសាស្ត្រសកលដើម្បីកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងដែលបង្កគ្រោះថ្នាក់»*[26] *ត្រូវបានអនុម័តជាឯកច្ឆន្ទៈនៅឯមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៦៣ ក្នុងឆ្នាំ២០១០។ គោលបំណងនៃយុទ្ធសាស្ត្រសកលនេះគឺដើម្បីកាត់បន្ថយអត្រាជំងឺ និងមរណភាពទាក់ទងនឹងគ្រឿងស្រវឹង ព្រមទាំងបង្កផលប៉ះពាល់ដល់សង្គម និងដើម្បីលើកកម្ពស់សុខភាពបុគ្គល គ្រួសារ និងសង្គមដើម្បីទប់ស្កាត់នូវផលប៉ះពាល់នៃគ្រឿងស្រវឹងដែលជាកត្តាធំ*

*ទី ៣ ដែលជះឥទ្ធិពលអាក្រក់ដល់សុខភាព និងសង្គមនៅលើពិភពលោក។ ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រនេះទាមទារឱ្យមានវិធានការទូលំទូលាយរួមមាន ការរឹតត្បិតការផ្សាយពាណិជ្ជកម្ម ការហាមឃាត់ ឬការរឹតត្បិតលើការលក់តថ្លៃ និងការលក់បែបផឹកមិនកំណត់ និងការបង្កើនតម្លៃគ្រឿងស្រវឹងតាមរយៈពន្ធ និងប្រព័ន្ធតម្លៃអប្បបរមា។*[26]




**រូបទី ១០.៧៖** វិធានការសង្គម (សារព្រមាននៅលើកញ្ចប់ថ្នាំជក់)

## អត្ថបទដកស្រង់ ១០.៨៖ របៀបប្រើប្រាស់ឱសថ

*ទោះបីជាឱសថត្រូវបានផលិតឡើងក្នុងគោលបំណងបង្ហាញពីប្រសិទ្ធភាពរបស់វាក្នុងការធ្វើឱ្យជំងឺ និងវិបត្តិសុខភាពនានារបស់មនុស្សប្រសើរឡើងក៏ដោយ ប៉ុន្តែចាំបាច់ត្រូវប្រើប្រាស់ឱ្យបានត្រឹមត្រូវ ពីព្រោះសូម្បីតែឱសថដែលមានអត្ថប្រយោជន៍ក៏អាចមានផលប៉ះពាល់ដល់សុខភាពដែរប្រសិនបើប្រើប្រាស់ក្នុងផ្លូវខុស។ ជាទូទៅឱសថមាន «**ផលល្អ**» ដែលសម្រេចបំណងនៃការបន្ធូរបន្ថយ និងព្យាបាលរោគសញ្ញានៃជំងឺ និង «**ផលអាក្រក់**» គឺមានឥទ្ធិពលអវិជ្ជមានលើរាងកាយដែលបណ្ដាលមកពីការប្រើប្រាស់ឱសថ។ ផលអាក្រក់អាចកើតមានជាមួយឱសថណាមួយក៏បាន ហើយក៏អាចកើតមានចំពោះអ្នកដែលមានសម្បទាពីកំណើត ឬលក្ខខណ្ឌណាមួយ។*

*ឱសថគឺជាថ្នាំដែលត្រូវបានរចនាឡើងដើម្បីប្រើប្រាស់ក្នុងការធ្វើរោគវិនិច្ឆ័យ ការព្យាបាល ឬការការពារជំងឺរបស់មនុស្ស និងសត្វ។ ឱសថទាំងនោះមានធាតុផ្សំ និងទម្រង់ផ្សេងៗ (ឧទាហរណ៍ ថ្នាំទម្រង់រាវ ទម្រង់ពាក់កណ្ដាលរឹង និងទម្រង់រឹង) ដែលសមស្របសម្រាប់ប្រសិទ្ធភាព (effect) និងភាពសក្ដិសិទ្ធ (efficacy) (ឧទាហរណ៍ បំបាត់ការឈឺចាប់)។ លើសពីនេះទៅទៀត ការប្រើប្រាស់ (ដូសកម្រិត ព្រមទាំងការគ្រប់គ្រង និងពេលវេលា) ត្រូវបានបង្កើតឡើង ដូច្នេះឱសថអាចបង្ហាញពីប្រសិទ្ធភាព និងភាពសក្ដិសិទ្ធបានត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែឱសថក៏មានហានិភ័យបង្កផលប៉ះពាល់ដែរប្រសិនបើប្រើក្នុងផ្លូវខុស។ ឧទាហរណ៍ ប្រសិនបើអ្នកខកខានលេបថ្នាំដែលត្រូវការលេបបីដងក្នុងមួយថ្ងៃហើយលេបថ្នាំទ្វេដងក្នុងពេលតែមួយកម្រិតថ្នាំនៅក្នុងឈាមអាចកើនឡើងដល់កម្រិតគ្រោះថ្នាក់ដែលអាចបណ្ដាលឱ្យមានប្រតិកម្មថ្នាំ។ ឬប្រសិនបើអ្នកផ្លាស់ប្ដូរដូសកម្រិតថ្នាំហើយលេបក្រោមកម្រិតដូសថ្នាំសម្រាប់ព្យាបាលនាំឱ្យកម្រិតថ្នាំក្នុងឈាមនឹងទាបពេកមិនអាចធ្វើឱ្យមានភាពសក្ដិសិទ្ធ (**រូបទី ១០.៨**)។ ដូច្នេះក្នុងការប្រើប្រាស់ថ្នាំពេទ្យ វាចាំបាច់ណាស់ត្រូវពិគ្រោះជាមួយគ្រូពេទ្យ ឱសថការី ឬបុគ្គលិកឱសថស្ថានដោយប្រុងប្រយ័ត្នអំពីការប្រើប្រាស់ថ្នាំ និងត្រូវធ្វើតាមកម្រិតដូស និងការគ្រប់គ្រងដែលមានសរសេរនៅលើកញ្ចប់។*[27]

***ឱសថមានគុណភាពទាប និងឱសថក្លែងក្លាយ*** *រួមទាំងឱសថមានស្លាកចំណុះ និងគ្រឿងផ្សំក្លែងក្លាយ ឱសថដែលមិនត្រូវតាមស្តង់ដា ឬលក្ខណៈបច្ចេកទេស និងឱសថដែលមិនត្រូវបានវាយតម្លៃ ឬអនុម័តដោយអាជ្ញាធរ*

*គ្រួតពិនិត្យកំពុងកើនឡើងយ៉ាងឆាប់រហ័សនៅតំបន់អាស៊ី អាមេរិកខាងត្បូង និងអឺរ៉ុប។ ការស្ទង់មតិរបស់ WHO[28] បានរាយការណ៍ថា ឱសថដែលមានគុណភាពទាប និងឱសថក្លែងក្លាយមានចំនួនប្រហែល ១០,៥% នៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម។ របាយការណ៍បានលើកឡើងផងដែរថា ឱសថទាំងនេះប៉ះពាល់ជាពិសេសដល់ជំងឺរលាកសួត និងជំងឺគ្រុនចាញ់ដែលកើតឡើងលើកុមារ។ វាមានការព្រួយបារម្ភថា ការរីកដុះដាលអ៊ីនធឺណែតអាចបង្កើនការលក់ឱសថតាមអ៊ីនធឺណែតដែលមានគុណភាពទាប និងឱសថក្លែងក្លាយបាន។*

*នៅប្រទេសកម្ពុជាភាគរយប៉ាន់ស្មាននៃឱសថទាំងនេះប្រែប្រួលយ៉ាងទូលំទូលាយពី ៤%-៩០%។ ជាពិសេសត្រូវមានការប្រុងប្រយ័ត្ន ចំពោះឱសថដែលលក់ធូរថ្លៃតាមហាងក្នុងសហគមន៍ដោយសារវាជាឱសថមានគុណភាពទាប ឱសថក្លែងក្លាយ ឬឱសថដែលគ្មានការអនុញ្ញាតពីក្រសួងជំនាញ។[29] ដូច្នេះគួរប្រើប្រាស់ឱសថដែលទទួលបានពីកន្លែងដែលអាចទុកចិត្តបានដូចជា មន្ទីរពេទ្យ និងឱសថស្ថាន។*




ប្រភព៖ Risk/Benefit Assessment of Drugs - Analysis and Response. Kusuri Guidebook. Copyright ©RAD-AR Council, Japan. All rights Reserved. Translated with permission

**រូបទី ១០.៨៖** កម្រិតថ្នាំក្នុងឈាម និងភាពសក្តិសិទ្ធរបស់ថ្នាំ[27]

## ☞ លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម

[១០-១] ចំពោះការរឹតត្បិតលើការផ្សាយពាណិជ្ជកម្មសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹង វាមាន «ការហាមឃាត់ការផ្សាយពាណិជ្ជកម្មទាក់ទាញដល់អនីតិជន» នៅប្រទេសកាណាដា និង «ការហាមឃាត់ការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ និងភាពយន្ត» នៅប្រទេសបារាំង។ សូមពិចារណាថា តើវិធានការសង្គមបែបណាដែលអាចអនុវត្តនៅក្នុងប្រទេសកម្ពុជាដើម្បីបង្កើតបរិយាកាសសម្រាប់ទប់ស្កាត់ការប្រើប្រាស់ថ្នាំជក់ និងគ្រឿងស្រវឹងក្នុងចំណោមកុមារ។

[១០-២] អ្នកជក់បារីនិយាយថា ពួកគេមានអារម្មណ៍ស្រស់ស្រាយបន្ទាប់ពីជក់បារីហើយពួកគេមិនអាចទ្រាំអត់ជក់បារីបានទេនៅពេលដែលពួកគេមានអារម្មណ៍តានតឹង។ បង្ហាញមតិជំទាស់របស់អ្នកប្រឆាំងនឹងមតិទាំងនេះ។

[១០-៣] ចូរពិចារណាអំពីអ្វីដែលអ្នកត្រូវការដើម្បីបង្កើតសង្គមមួយដែលគ្មានគ្រឿងញៀន។

[១០-៤] ចូរស្វែងយល់ពីទំនាក់ទំនងរវាងអាកប្បកិរិយាដែលមានហានិភ័យទាក់ទងនឹងថ្នាំជក់ គ្រឿងស្រវឹង និងការរួមភេទហើយពិចារណាអំពីមូលហេតុដែលយុវជនបង្ហាញអាកប្បកិរិយាទាំងនោះ។

[១០-៥] ចូរពិចារណាអំពីអ្វីដែលគួរធ្វើដើម្បីឱ្យកុមារបដិសេធនៅពេលនរណាម្នាក់ឱ្យគ្រឿងញៀនទៅពួកគេ។

[១០-៦] ចូរពិចារណាអំពីវិធីដែលគ្រូបង្រៀនគួរធ្វើសកម្មភាពបើកុមាររាយការណ៍ថា គាត់បានឃើញមនុស្សប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬជួញដូរគ្រឿងញៀននៅក្នុងតំបន់ដែលកុមារនោះរស់នៅ។

[១០-៧] ចូរស្រាវជ្រាវអំពីការរឹតត្បិតដំណាំកញ្ឆានៅកម្ពុជា។ ចូរសិក្សាពីរបៀបដែលកញ្ឆាត្រូវបានគេប្រើប្រាស់ជាលក្ខណៈប្រវត្តិសាស្ត្រ និងវប្បធម៌នៅប្រទេសកម្ពុជា។

## ឯកសារយោង៖


1. Ministry of Health, Labour and Welfare: e-healthnet “Health effects of tobacco use”
   https://www.e-healthnet.mhlw.go.jp/information/tobacco-summaries/t-02
2. CDC. Smoking, Pregnancy, and Babies.
   https://www.cdc.gov/tobacco/campaign/tips/diseases/pregnancy.html
3. WHO: Health effects of smoking among young people.
   https://apps.who.int/tobacco/control/populations/youth_health_effects/en/index.html
4. WHO: Heat-Not-Burn tobacco products information sheet
   https://apps.who.int/tobacco/publications/prod_regulation/heat-not-burn-products-information-sheet/en/index.html
5. WHO: WHO Framework Convention on Tobacco Control. 2003
   https://www.who.int/fctc/text_download/en/
6. Chheng N. New tobacco device banned. The Phnom Penh Post. March 21, 2021
   https://www.phnompenhpost.com/national/new-tobacco-device-banned
7. Ministry of Health, Labour and Welfare: e-healthnet “Health effects of alcohol”
   https://www.e-healthnet.mhlw.go.jp/information/alcohol-summaries/a-01
8. Ministry of Health, Labour and Welfare: e-healthnet “Alcohol and dependence”
   https://www.e-healthnet.mhlw.go.jp/information/alcohol-summaries/a-05
9. Ministry of Health, Labour and Welfare: e-healthnet “Alcohol and social issues”
   https://www.e-healthnet.mhlw.go.jp/information/alcohol-summaries/a-06
10. WHO Western Pacific Region Office. Young People and Alcohol: A Resource Book. 2015
    https://apps.who.int/iris/bitstream/handle/10665/208202/9789290616849_eng.pdf?sequence=1&is Allowed=y
11. Dharmapuri S, Miller K, Klein JD. Marijuana and the Pediatric Population. Pediatrics. 146 (2) e20192629. 2020
    https://pediatrics.aappublications.org/content/146/2/e20192629
12. Global News View: “The Golden Triangle—Rapidly increasing stimulants”
    https://globalnewsview.org/archives/9905
13. United States Drug Enforcement Administration. Drug Fact Sheet: Narcotics.
    https://www.dea.gov/sites/default/files/2020-06/Narcotics-2020.pdf
14. WHO: Report on the global tobacco epidemic 2019 -Country report Cambodia-
    https://www.who.int/tobacco/surveillance/policy/country_profile/khm.pdf
15. National Institute of Statistics, Ministry of Planning, Cambodia: National Adult Tobacco survey of Cambodia, 2014
    https://untobaccocontrol.org/impldb/wp-content/uploads/cambodia_2018_annex-1_national_adult_tobacco_survey_report_2014.pdf
16. WHO: Global Youth Tobacco Survey 2016 -Country Report Cambodia-
    https://extranet.who.int/ncdsmicrodata/index.php/catalog/690/related_materials
17. WHO: Global Status Report on Alcohol and Health. 2018
    https://www.who.int/substance_abuse/publications/global_alcohol_report/gsr_2018/en/
18. WHO Cambodia - Global School-Based Student Health Survey 2013
    https://extranet.who.int/ncdsmicrodata/index.php/catalog/220/data_dictionary
19. The Asia Foundation. The Alcohol Industry in Cambodia -A Study of Taxation, Regulation, Distribution, and Consumption of Alcohol-. 2016
    https://think-asia.org/bitstream/handle/11540/7313/The-Alcohol-Industry-in-Cambodia_report.pdf?sequence=1
20. Ministry of Education, Youth and Sports, Cambodia: Most at Risk Young People Survey Cambodia. 2010
    https://healtheducationresources.unesco.org/library/documents/most-risk-young-people-survey-cambodia-2010
21. UNODC: Synthetic Drugs in East and South-East Asia: Latest developments and challenges. 2020
    https://www.unodc.org/documents/scientific/ATS/2020_ESEA_Regonal_Synthetic_Drug_Report_web.pdf
22. AIPA Council on Dangerous Drugs: Country Report of Cambodia-. 2019
    https://www.parliament.go.th/ewtadmin/ewt/aipa2019/download/article/AIPACODD/Annex%20J%20-%20Country%20Report%20of%20Cambodia.pdf
23. Good Neighbors Cambodia: Survey Report -The Child’s Reporting on The Situation of Drug Use in Community-. 2019
    http://www.gncambodia.org/wp-content/uploads/2019/11/GNC_Drug-Survey-Reported-by-Voluntary-Grassroots-Youth-EN.pdf
24. Peltzer K, Pengpid S, Tepirou C. Associations of alcohol use with mental health and alcohol exposure among school-going students in Cambodia, Nagoya Journal of Medical Science. 78(4): 415–422.2016.
    https://www.ncbi.nlm.nih.gov/pmc/articles/PMC5159467/
25. Banta JE, Addison A, Job JS, Yel D, Kheam T, et.al. Patterns of Alcohol and Tobacco Use in Cambodia.
    Asia Pac J Public Health. 25(5 Suppl): 33S–44S, 2013
    https://www.ncbi.nlm.nih.gov/pmc/articles/PMC5043075/

26. WHO: Global strategy to reduce the harmful use of alcohol. 2010
https://www.who.int/substance_abuse/alcstratenglishfinal.pdf
27. RAD-AR Council, Japan. KUSURI GUIDEBOOK.
https://www.rad-are.com/downloads/kusurigb-pdf02.pdf
28. WHO: WHO Global surveillance and monitoring system for substandard and falsified medical products. 2017.
https://www.who.int/medicines/regulation/ssffc/publications/GSMS_Report.pdf
29. Khan MH, Okumura J, Sovannarith T, Nivanna N, Nagai H, et al. Counterfeit Medicines in Cambodia—Possible Causes. Pharmaceutical Research 28:484-489. 2010
https://www.researchgate.net/publication/47157896_Counterfeit_Medicines_in_Cambodia-Possible_Causes